# ការអប់រំនៅកម្ពុជា

មួយថ្ងៃបន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសនាថ្ងៃទី ២៣ ខែតុលាឆ្នាំ ១៩៩១ ស្តីពីកម្ពុជា ខ្ញុំបានសំរេចចិត្តវិលត្រឡប់មក ប្រទេសខ្ញុំវិញ ដើម្បីចូលរួមក្នុងការស្ថាបនា ជាពិសេសលើវិស័យអប់រំ។

ខ្ញុំសង្ឃឹមថា បទពិសោធន៍របស់ខ្ញុំ ជាគ្រូបង្រៀន ១៤ ឆ្នាំនៅកម្ពុជា និង ១៣ ឆ្នាំនៅប្រទេសបារាំង អាចមានប្រយោជន៍សម្រាប់ប្រទេសកំណើតរបស់ខ្ញុំដែលត្រូវបានបំផ្លាញដោយសង្គ្រាមជាច្រើនឆ្នាំ។

ការបោះឆ្នោតនីតិបញ្ញត្តិឆ្នាំ ១៩៩៣ រៀបចំឡើងដោយអ៊ុនតាក់ ជាឱកាសសម្រាប់ខ្ញុំដើម្បីអាចចូលរួមយ៉ាងសកម្មក្នុងការកសាងប្រទេសកម្ពុជាដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមជាច្រើនឆ្នាំមកហើយ។ ខ្ញុំបានឈរឈ្មោះជាបេក្ខជន របស់គណបក្សសេរីនិយមមួយ ក្នុងខេត្តតាកែវដែល ជាខេត្តកំណើតរបស់លោកឪពុករបស់ខ្ញុំ។

ប៉ុន្តែដោយសារការគំរាមកំហែង និងការបំភិតបំភ័យ ជាច្រើនពីអាជ្ញាធរមូលដ្ឋាន ខ្ញុំមិនអាចធ្វើការឃោសនា បានធម្មតាទេ។ក្រោយពីការបោះឆ្នោតខ្ញុំក៏បានត្រឡប់មកប្រទេសបារាំងវិញ ដើម្បីបន្តមុខងារជាគ្រូបង្រៀននៅប្រទេសបារាំងវិញ។

តែមុនពេលដែលខ្ញុំត្រូវចូលនិវត្តន៍នៅឆ្នាំ ២០០១ ខ្ញុំបានផ្ញើបេក្ខភាពរបស់ខ្ញុំម្តងទៀត ក្នុងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់រដ្ឋាភិបាលកម្ពុជា ដែលបានបដិសេធសំណើររបស់ខ្ញុំ។

ក្នុងរបបខ្មែរក្រហម ការអប់រំត្រូវបានបរាជ័យយ៉ាងធ្ងន់ធ្ងរ ហើយការបោះជំហានដ៏ធំធេងក្នុងវិស័យអក្ខរកម្ម និង ការអប់រំក្នុងរយៈពេលពីរទសវត្សរ៍បន្ទាប់ពីឯករាជ្យភាព ត្រូវបានបំផ្លាញជាប្រព័ន្ធ។ សាលារៀនត្រូវបានបិទ។ មនុស្សដែលមានការអប់រំ និង គ្រូបង្រៀនត្រូវបានទទួល ការសង្ស័យ និង ការព្យាបាតយ៉ាងឃោរឃៅជាទីបំផុត។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៧០ គ្រូបង្រៀនជាង ២ ម៉ឺននាក់បានរស់នៅក្នុងប្រទេសកម្ពុជា។១០ ឆ្នាំក្រោយមក គ្រូបង្រៀននៅសល់ តែប្រហែល ៥.០០០ នាក់ប៉ុណ្ណោះ។

ចាប់ពីការបោះឆ្នោតនីតិកាល ១៩៩៣ រហូតមកដល់បច្ចុប្បន្ននេះ ដោយសារតែអស្ថិរភាពនយោបាយ និង អវត្តមាន នៃ លទ្ធិប្រជាធិបតេយ្យពិតប្រាកដ នៅក្នុងប្រទេស គ្មានអ្វីជាប្រសើដែលបានធ្វើ ក្នុងប្រព័ន្ធអប់រំមូលដ្ឋានឡើយ។

ខ្ញុំចង់ចែករំលែកជាមួយអស់លោក លោកស្រីនៅទីនេះ នូវការវិភាគរបស់ខ្ញុំ ផ្តោតទៅលើការអប់រំកុមារ។ ក្រោយពីរបបខ្មែរក្រហមមក យុវជនដែលបានរួចជីវិតពីរបបនេះ មិនបានចេះ សូម្បីតែ ភាសាខ្លួនឯងផង (ការសរសេរ ការនិយាយ ពាក្យអសុរសជាដើម)។

ពួកគេគ្រាន់តែដឹងអំពីការភ័យខ្លាច ការឃ្លាន និងការថ្កោលទោស។ សាមគ្គីភាពក្នុងគ្រួសារត្រូវបានបែកបាក់គ្នា ភាពថ្លៃថ្នូរ និង ការគោរពចំពោះអ្នកដទៃបានបាត់បង់។ មានតែអង្គការទេដែលគ្រប់គ្រងការរស់នៅរបស់ពួកគេ។

ប៉ុន្មានទសវត្សរ៍ក្រោយមក យុវជនទាំងនេះបានក្លាយទៅជាមេគ្រួសារ ពួកគេក៏គ្មានអ្វីត្រូវបញ្ជូនបន្ត ទៅកូន ៗ របស់ពួកគេនោះទេ។ យុវជនមួយចំនួនធំ ពាក់ព័ន្ធទៅ នឹង គ្រឿងញៀន គ្រឿងស្រវឹង និងអំពើហឹង្សា។ សីលធម៌កំពុងធ្លាក់ចុះនៅគ្រប់ស្រទាប់នៃសង្គម។

សរុបសេចក្តីមក វាជាការបន្ទាន់ ហើយដើម្បីឱ្យស្របទៅនិងកិច្ចព្រមព្រៀងទីក្រុងប៉ារីសនាថ្ងៃទី ២៣ ខែតុលាឆ្នាំ ១៩៩១ យើងត្រូវតែស្តារលទ្ធិប្រជាធិបតេយ្យពិតប្រាកដ និង យូរអង្វែងនៅកម្ពុជា ដែលអាចឱ្យមេដឹកនាំប្រទេសអាចដោះស្រាយបានយ៉ាងឆាប់រហ័ស នូវស្ថានភាពដ៏គួរឱ្យរន្ធត់ដែលរាស្ត្រខ្មែរបច្ចុប្បន្នកំពុងជាប់ប្រទេះ។

ដោយសារមូលហេតុដែលខ្ញុំបានរៀបរាប់ខាងលើ  ការអប់រំនៅកម្ពុជាកំពុងឆ្លងកាត់វិបត្តិដ៏ធ្ងន់ធ្ងរ ដែលតម្រូវឱ្យមានសន្ទុះក្នុងការដោះស្រាយជាបន្ទាន់។ អស់រយៈពេលជាច្រើនឆ្នាំកម្រិតបានធ្លាក់ចុះវិសមភាពបានពង្រីកហើយវិជ្ជាជីវៈបង្រៀនមិនត្រូវបានផ្តល់តម្លៃទេ។ កម្ពុជានេះ មិនមែនជាកម្ពុជាដែលខ្ញុំចង់បាននោះទេ។ កម្ពុជារបស់ខ្ញុំ ត្រូវផ្តល់ឱកាស ដល់កុមារគ្រប់រូបតាមរយៈសាលារៀន។

ខ្ញុំសូមអរគុណចំពោះ ការយកចិត្តទុកដាក់ស្តាប់របស់លោកអ្នក។

ឡុង សូរី

អ៊ីហ្សានវីល ថ្ងៃទី ១១ ខែតុលាឆ្នាំ ២០២១